# សំណង់រចនាសម្ព័ន្ធអាងស្តុកទឹកនៅបឹងមាលា និងបាកាណ

នៅក្នុងបរិបទអ្នកស្រាវជ្រាវ កាលណាគេនិយាយអំពីអាងស្តុកទឹកធំៗឬសំខាន់ៗនៅតាមទីតាំងបុរាណដ្ឋានផ្សេងៗ គេច្រើនហៅអាងស្តុកទឹកនោះថា "បារាយណ៍"។ ប៉ុន្តែ បើយើងយកពាក្យនេះមកពិចារណាឡើងវិញ ពាក្យ "បារាយណ៍" ទំនងគេមិនហៅសំដៅលើអាងស្តុកទឹកនោះទេពោល ទំនងគេហៅសំដៅព្រះនាមទេពមួយអង្គក្នុងព្រហ្មញ្ញសាសនាដែលយើងស្គាល់ថា "ព្រះនារាយណ៍"។ ដ្បិត ពាក្យ "បារាយណ៍" នេះ ទំនងក្លាយមកពីពាក្យថា "ព្រះនារាយណ៍" (*សូមមើល ម៉ង់ វ៉ាលី, ២០២១: ទំ. ៥៤-៦៤*)។ ដោយឡែក អាងស្តុកទឹកនៅបឹងមាលា អ្នកស្រុកមិនដែលហៅថា "បារាយណ៍" នោះទេ ពោល គឺគេហៅថា "បឹង"។[១] ចំណែក អាងស្តុកទឹកនៅបាកាណ (អ្នកស្រាវជ្រាវបារាំងហៅថា "ព្រះខ័ន-កំពង់ស្វាយ") អ្នកស្រុកហៅថា "បដាក"។[២]

អាងស្តុកទឹកនៅបឹងមាលា មានរាងបួនជ្រុងទ្រវែងដែលមានទំហំបណ្តោយ ១៥៥០ម៉ែត្រ និងទទឹង ៧៩០ម៉ែត្រ។ បឹងនេះស្ថិតនៅខាងកើតប្រាសាទបឹងមាលាភ្ជាប់គ្នាដោយស្ពានហាលនិងកសិន្ធុខាងកើត ដោយមានប្រាសាទផ្ទីជាផ្ចិតកណ្តាល (រូបលេខ១-២) និងមានប្រាសាទគង់ក្លុកនៅជ្រុងអាគ្នេយ៍ (រូបលេខ៣-៤) (សូមមើលប្លង់លេខ១) ប្រាសាទបឹងមាលា ជាសំណង់មួយដែលមានប្លង់ស្រដៀងប្រាសាទអង្គរវត្តដែលជាអ្នកស្រាវជ្រាវជាច្រើនយល់ថា សាងឡើងក្រោយប្រាសាទអង្គរវត្ត និងបញ្ចប់ការសាងសង់ក្នុងពេលមួយឆាប់រហ័សជាងប្រាសាទអង្គរវត្ត នៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ (គ.ស.១១១៣-១១៥០)។[៣] រចនាសម្ព័ន្ធរបស់អាងស្តុកទឹកបឹងមាលាដែលគួរឱ្យកត់សម្គាល់នោះគឺ ប្រាសាទផ្ទី ដែលសាងសង់ឡើងនៅចំកណ្តាលផ្ទៃបឹង។ ប្រាសាទនេះបានបាក់រលំទាំងស្រុង ហើយទើបជួសជុលរៀបចំឡើងវិញនៅឆ្នាំ២០២១ ដោយអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា។ ប្លង់ប្រាសាទនេះមានលក្ខណៈប្លែកពីប្លង់ប្រាសាទដទៃទៀតទាំងស្រុងតែម្តងពោល គឺគេតម្រៀបថ្មបាយក្រៀមជុំវិញចេញជារាងបួនជ្រុងស្មើ និងនៅចំកណ្តាលគេយកថ្មភក់តម្រៀបឲ្យចេញរាងមូលខ្ពស់ឡើងទៅលើដើម្បីជាទម្រព្រះពុទ្ធប្រក់នាគមួយអង្គ។ ប្រការមួយ

---

[១] ពាក្យ "មាលា" អ្នកស្រុកនៅកំពង់ធំនៅប្រើប្រាស់នៅឡើយ ពោលគឺហៅសំដៅលើផ្ទៃទឹកដែលទឹកឡើងជន់ដោរ ឬទឹកបែកសាច។ ម្ល៉ោះហើយ បឹងមាលា ទំនងគេហៅសំដៅផ្ទៃទឹកបឹងដែលហូរហៀរ ជន់ដោរ ដូចនឹងពាក្យថា "ទឹកបែកផ្កាត្រែង" ដូច្នោះដែរ។

[២] ពាក្យ "បដាក" ជាពាក្យហៅតាមសំនៀងខ្មែរដែលក្លាយមកពីពាក្យសំស្ក្រឹតថា "តដាក" ដែលសំដៅលើធារទឹកធម្មជាតិ ឬបឹងដែលមនុស្សជីក ត្រូវនឹងពាក្យក្នុងភាសាអង់គ្លេសថា "Pool"។

[៣] Boisselier 1952.

ដែលគួរឲ្យសោកស្តាយ ព្រះសិររបស់ព្រះពុទ្ធរូបបានបាត់បង់ពីទីតាំងដើម ហើយគេបានឆ្លាក់ព្រះសិរថ្មីមកជំនួសវិញ។[៤] រីឯប្រាសាទគង់ភ្លុកវិញ គឺជាប្រាសាទមួយដែលមានរាងពីរ៉ាមីតជាច្រើនថ្នាក់ៗ ធ្វើអំពីថ្មបាយក្រៀម មានកំពែងព័ទ្ធជុំវិញ និងច្រកចូលនៅកំពែងគ្រប់ទិសទាំងបួនធ្វើអំពីថ្មភក់។ នៅផ្នែកខាងត្បូងមានទីលានទាបមួយធ្វើអំពីថ្មភក់ភ្ជាប់គ្នាពីកំពែងប្រាសាទដោយអន្តរ។[៥] បើមើលតាមសិល្បៈ ស្ថាបត្យកម្ម ប្រាសាទផ្ទី និងប្រាសាទគង់ភ្លុក ទំនងសាងឡើងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (គ.ស.១១៨១-១២១៨)។

ដោយឡែក អាងស្តុកទឹកនៅតំបន់បាកាណវិញ (បដាក) មានរាងបួនជ្រុងទ្រវែងដែលមានបណ្តោយប្រវែង ២៩០០ម៉ែត្រ និងទទឹង ៧៥០ម៉ែត្រ។ បដាក មានកម្ពស់ដីពុំស្មើគ្នាឡើយ ដោយនៅផ្នែកខាងលិចខ្ពស់ជាងខាងកើត ម៉្លោះហើយទឹកនៅខាងកើតអាចប្រើប្រាស់ខួបប្រាំងនិងវស្សាបាន តែនៅខាងលិចវិញពុំសូវមានទឹកដក់ឡើយ។ សំណង់ដែលជារចនាសម្ព័ន្ធរបស់បដាកមានលក្ខណៈប្រហាក់ប្រហែលបឹងមាលាដែរ ពោល គឺនៅចំកណ្តាលមានប្រាសាទព្រះថ្កោល នៅជ្រុងអាគ្នេយ៍ផាកមុំមកខាងជើងបន្តិចមានប្រាសាទព្រះដំរី និងនៅខាងលិចមានប្រាសាទព្រះស្ទឹង (អ្នកស្រុកហៅប្រាសាទមុខបួន) (សូមមើលប្លង់លេខ២)។ ប្រាសាទព្រះស្ទឹងឬមុខបួន គេសង់នៅចំផ្ចិតកណ្តាលនៃផ្នែកខាងលិច ដែលទំនងជាសំណង់មានកំពូលមុខបួនឬមុខព្រហ្មដំបូងគេនៅក្នុងសិល្បៈខ្មែរ (រូបលេខ៥-៦) ពោល គឺអាចសាងក្នុងរជ្ជកាលព្រះបាទត្រីភូវនាទិត្យវរ្ម័ន (គ.ស. ១១៦៥-១១៧៧)។[៦] រីឯប្រាសាទព្រះថ្កោល ដែលជាសំណង់នៅកណ្តាលបដាកវិញ ពុំមានប្លង់ដូចប្រាសាទផ្ទីនៅកណ្តាលបឹងនៅបឹងមាលាឡើយ។ ប្រាសាទព្រះថ្កោលសាងសង់ឡើងអំពីថ្មភក់ មានផ្លូវចូលគ្រប់ទិសទាំងបួន តែផ្នែកខាងត្បូងនិងខាងជើងពុំមានជាសំណង់ទ្វារចូលមានដំបូលបែរដូចផ្នែកខាងលិចនិងខាងកើតឡើយ។ ប្រាសាទនេះមានហោត្រ័យចំនួនពីរនៅទិសខាងត្បូងនិងខាងជើង ដែលសង់បែរមុខមកទិសខាងលិច។ ប្រាង្គកណ្តាល មានរាងកាកបាទ មានទ្វារចេញចូលទាំងបួនទិស (រូបលេខ៧)។[៧] អ្វីដែលគួរកត់សម្គាល់ គឺនៅតាមជ្រុងនីមួយៗនៃប្រាង្គកណ្តាលមានលម្អជាសត្វមានតេជៈត្រួតលើគ្នាដែលមានដូចជា ហង្ស គ្រុឌ គោ ដំរី (រូបលេខ៨) ហើយទំនង

---

[៤] ឯកឧត្តម គឹម សុធិន អគ្គនាយករង នៃអាជ្ញាធរជាតិអប្សរាបានបញ្ជាក់នៅតាមបណ្តាញសង្គមហ្វេសបុករបស់ឯកឧត្តមថា "ប្លង់របៀបនេះទំនងមានតែមួយនៅស្រុកខ្មែរ ហើយព្រះសិរព្រះពុទ្ធរូបបានបាត់បង់"។

[៥] Lajonquieère 1902: 287.

[៦] Claude Jacques, Inscription K.1297 in "*The fragility of our history*", Lecutres in EFEO.

[៧] Mauger, 1939: 213.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ជាសំណង់រាជ្យព្រះបាទជ័យវរ្ម័នទី៧ដូចគ្នាដែរ។ ចំពោះប្រាសាទព្រះដំរីដែលនៅជ្រុងអាគ្នេយ៍បដាកវិញ មានប្លង់រាងពីរ៉ាមីតចំនួន១១ថ្នាក់ មានទ្វារចូលគ្រប់ទិសទាំងបួន (រូបលេខ៩) ពោល គឺមានប្លង់ជារួមដូចប្រាសាទគង់ក្ដុក ប៉ុន្តែមិនមានសំណង់ជាទីលានភ្ជាប់ទៅត្បូងដូចនៅគង់ក្ដុកទេ។ នៅផ្នែកខាងលើតាមជ្រុងនីមួយៗមានបដិមាដំរី និងនៅចំកណ្ដាលមានបដិមាគោ (រូបលេខ១០) ហើយនៅតាមជ្រុងកំពែងវិញ មានលម្អចម្លាក់សត្វជាច្រើនរួមបញ្ចូលគ្នាដូចនៅប្រាសាទព្រះថ្កោលដែរ (រូបលេខ១១)។ ប្រាសាទព្រះដំរី ក៏ជាសំណង់ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ដូចសំណង់ដែលបានរៀបរាប់ខាងលើដែរ។[៨]

សំណង់រចនាសម្ព័ន្ធជារួមរបស់អាងស្តុកទឹកដែលបានរៀបរាប់ទាំងពីរនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នា ពោលគឺមានសំណង់មួយនៅកណ្ដាលដូចគ្នា។ ប៉ុន្តែ ខុសត្រង់ថាទម្រង់ប្រាសាទផ្ទី និងប្រាសាទព្រះថ្កោលពុំដូចគ្នា។ អ្វីដែលគួរកត់សម្គាល់នោះគឺ នៅជ្រុងអាគ្នេយ៍មានប្រាសាទរាងពីរ៉ាមីតដូចគ្នា ពោល គឺនៅបឹងមាលាមានប្រាសាទគង់ក្ដុក និងនៅបាកាណមានប្រាសាទព្រះដំរី។ ប្រាសាទទាំងពីរនេះ សុទ្ធសឹងជាប់ទាក់ទងនឹងសត្វដំរីដូចគ្នា។ នៅរឿងព្រេងខ្មែរ គឺ"រឿងស្ដេចដំរីស" ឬ "នាងទន់សត្រា" ក៏មានរៀបរាប់អំពីប្រាសាទទាំងពីរដែរ។ ក្នុងសាស្ត្រាមួយរៀបរាប់ថា "*នៅពេលមួយស្ដេចដំរីស បានបំផ្លាញប្រាសាទនេះដើម្បីរកនាងទន់សត្តាជាបុត្រីរបស់ទ្រង់ ហើយដោយភាពហត់នឿយក្នុងការតាមរកនាងមិនឃើញ ក៏បានដាក់នៅលើប្រាសាទនេះ ទើបប្រាសាទនេះឈ្មោះថា គង់ក្ដុក*។[៩] រីឯក្នុងសាស្ត្រាមួយទៀតបានរៀបរាប់ថា "*ប្រាសាទព្រះដំរីបានបាក់បែកដោយសារស្ដេចដំរីសតាមរកបុត្រីរបស់ទ្រង់*"[១០] ទោះបីជាយ៉ាងណា នេះគ្រាន់តែទិន្នន័យមកពីរឿងព្រេងខ្មែរប៉ុណ្ណោះ ប៉ុន្តែ ប្រសិនយើងគិតតាមទស្សនៈសាសនាវិញ នៅក្នុងព្រហ្មញ្ញសាសនាដំរីឲ្វតជាយានជំនិះរបស់ព្រះឥន្ទ្រ ដែលជាស្ដេចនៅស្ថានសួគ៌និងជាលោកបាលប្រចាំនៅទិសខាងកើត ហើយសត្វដំរីគេបានចាត់ទុកជាសត្វមានតេជៈនៅការពារស្ថានអាទិទេព (ភ្នំមេរុ)។ នៅក្នុងពុទ្ធសាសនាវិញ សត្វដំរីជាសត្វមួយដែលមានរៀបរាប់ក្នុងពុទ្ធប្រវត្តិ ពោល គឺថ្វាយចង្ហាន់ដល់ព្រះពុទ្ធអង្គ និងមានដំរីមួយទៀតឈ្មោះបាលីលេយ្យដែលបានបម្រើដល់ព្រះពុទ្ធអង្គគង់ចាំព្រះវស្សានៅព្រៃបាលិលេយ្យ។ យើងជឿជាក់ថា ការសាងសំណង់រាងពីរ៉ាមីតនៅ

---

[៨] Claude & Phillipe 2007:120.

[៩] Phin Phakdey 2012: 25.

[១០] Ibid, p.26.

ជ្រុងអាគ្នេយ៍អាងស្តុកទឹករបៀបនេះ ទំនងជាមានគំនិតអ្វីមួយទាក់ទងនឹងគម្ពីរនៃសាសនា ប៉ុន្តែ យើងមិនទាន់ដឹងជាក់លាក់អំពីមូលហេតុជាក់លាក់នៅឡើយ។

## ឯកសារយោង

**ម៉ង់ វ៉ាលី**

២០២១, *កំពង់ធំ ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ*, ភ្នំពេញ

**Boisselier, Jean**

1952, Beng Mealea et lachronologie des monuments du style d’Angkor Vat, *BEFEO*, Tome 46, Paris.

**Claude, J. & Phillipe, L.**

2007, “*The Khmer empire cities and sanctuaries from the 5th to 13th century,* River Books, Bangkok

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

**Mauger, Henri**

1939, “Pràh Khãn de Kompoṅ Svay”, *BEFEO*, Tome 39: 106-120, Paris

**Phin Phakdey**

2012, *A critical analysis and text edition on a Khmer Manuscript : A case study on the folktale Satra Lom-ang Romchek,* Master thesis, Sophia University, Tokyo

AMS




ប្លង់លេខ១៖ ប្លង់ពីលើអាកាសបង្ហាញទីតាំងសំណង់រចនាសម្ព័ន្ធនៅអាងស្តុកទឹកបឹងមាលា

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៖ ប្រាសាទផ្ចី មើលពីទិសខាងកើត (រូបថត៖ ឡុន ណាក់)



រូបលេខ២៖ ប្រាសាទផ្ចី មើលពីទិសពាយព្យ (រូបថត៖ ឡុន ណាក់)



រូបលេខ២៖ លម្អិតព្រះពុទ្ធរូបនៅប្រាសាទថ្មី មើលពីទិសខាងកើត (រូបថត៖ ឡុន ណាក់)



រូបលេខ៣៖ ប្រាសាទគង់ភ្លុក មើលពីទិសនិរតី (រូបថត៖ ឡុន ណាក់)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ ប្រាសាទគង់ភ្លុក មើលពីខាងត្បូង (រូបថត៖ អេង តុលា)




ប្លង់លេខ២២៖ ប្លង់មើលពីលើអាកាសបង្ហាញសំណង់រចនាសម្ព័ន្ធបដាកនៅតំបន់បាកាណ



រូបលេខ៥៖ ប្រាសាទមុខបួន ឬព្រះស្ទឹង (រូបថត៖ ថៃ ឈាងម៉េង)



រូបលេខ៦៖ ចម្លាក់មុខព្រហ្មនៃប្រាសាទមុខបួន ឬព្រះស្ទឹង (រូបថត៖ ថៃ ឈាងម៉េង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបទី៧-៨៖ ប្រាសាទព្រះថ្កោល និងរូបចម្លាក់សត្វទេព (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ៩៖ ប្រាសាទដំរី (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១០៖ បដិមាដំរីនៅជ្រុងប្រាសាទដំរី តំបន់បាកាណ



រូបលេខ១១៖ ចម្លាក់សត្វរួមបញ្ចូលគ្នានៅតាមជ្រុងកំពែងប្រាសាទដំរី (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី